ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ
ក្រុមលទ្ធកម្ម
លេខ...២២១/១៩...ក.ល/មអជ.ក្រច

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការងារជួសជុលអគារសម្រាប់ដាក់សម្ភារៈ(បញ្ជប់) ជូនមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត សម្រាប់ឆ្នាំ២០១៩

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន /សហគ្រាស ( គិតទាំសហគ្រាសឯកត្តបុគ្គល)ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ឲ្យបានជ្រាបថា៖ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការ ការងារជួសជុលអគារសម្រាប់ដាក់សម្ភារៈ(បញ្ជប់) ជូនមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ សម្រាប់ឆ្នាំ២០១៩។

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានរៀបចំឯកសារ សម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញ ដើម្បីចូលរួមដេញថ្លៃ។ ឯកសារដេញថ្លៃមានដាក់លក់ នៅក្រុមលទ្ធកម្មមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ ដែលមានអាសយដ្ឋាន ភូមិក្រចេះ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ ចាប់ពីថ្ងៃទី...១៤...ខែសីហា...ឆ្នាំ២០១៩...តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០៧២ ៩៧១ ៥៥៣ ) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនក្រុមលទ្ធកម្ម យ៉ាងយូរបំផុតត្រឹមថ្ងៃទី...១៣...ខែកញ្ញា.... ឆ្នាំ២០១៩.... វេលាម៉ោង...១០:០០..........។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅ នៅក្រុមលទ្ធកម្ម តាមអាសយដ្ឋានខាងលើវេលាម៉ោង...១០:០០ ថ្ងៃទី...១៣.....ខែ...កញ្ញា......... ឆ្នាំ...២០១៩...។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ថ្ងៃសុក្រ ៣រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ធ្វើនៅក្រចេះ ថ្ងៃទី...១៦... ខែសីហា... ឆ្នាំ២០១៩
**ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត**
**និងជា ប្រធានក្រុមលទ្ធកម្ម**

**លឹម ដារ៉ាហាង**

**ចម្លងជូន ៖**
- *អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ*
- *អង្គភាពប្រឆាំងអំពើពុករលួយ*
- *ឯកសារ-កាលប្បវត្តិ*